- គណៈកម្មការនេះ ត្រូវប្រជុំបែងចែកភារកិច្ចជាក់ស្តែង និងរិះរកវិធានការថែមទៀតដើម្បីដំណើរការរុករកសង្គ្រោះយន្តហោះ និងនាវាអោយមានប្រសិទ្ធភាព ។
- រាល់សកម្មភាពរុករកសង្គ្រោះយន្តហោះ និងនាវាពេលមានឧប្បត្តិហេតុគណៈកម្មការត្រូវសរុបរបាយការណ៍ ព្រមទាំងការចំណាយផ្សេងៗ ក្នុងពេលចុះបំពេញបេសកកម្ម ដើម្បីដាក់ជូនរាជរដ្ឋាភិបាលជ្រាប និង សំរេច ។
- គណៈកម្មការនេះ មានសិទ្ធិប្រើប្រាស់ត្រារបស់ក្រសួងការពារជាតិ ។

**ប្រការ ៣** : សេចក្តីសំរេចលេខ៨៩ សសរ ចុះថ្ងៃទី ២៥-១២-១៩៩៥ របស់រាជរដ្ឋាភិបាលស្តីពីការបង្កើតគណៈកម្មការសំរាប់រុករកជួយសង្គ្រោះយន្តហោះពេលមានឧប្បត្តិហេតុ ចាត់ទុកជានិរាករណ៍ ។

**ប្រការ ៤** : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ អនុរដ្ឋលេខាធិការ គ្រប់ក្រសួង និងគ្រប់រដ្ឋលេខាធិការដ្ឋានដែលមានការពាក់ព័ន្ធ និងបណ្តាឯកឧត្តមដែលមាននាមក្នុងប្រការ ១ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសំរេចនេះ អោយមានប្រសិទ្ធភាពចាប់ពីថ្ងៃឡាយព្រះហស្តលេខា និង ចុះហត្ថលេខាតទៅ ។

| នាយករដ្ឋមន្ត្រីទី ១ | នាយករដ្ឋមន្ត្រីទី ២ |
|---|---|
| ព្រះហស្តលេខានិងត្រា | ហត្ថលេខានិងត្រា |
| **នរោត្តម រណឫទ្ធិ** | **ហ៊ុន សែន** |

* * *

ភ្នំពេញ, ថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ១៩៩៦

## សេចក្តីសំរេចលេខ ១៧ សសរ

## ស្តីពីគណៈកម្មការរៀបចំការអនុម័ត រាល់វិធាន ការការពារបេតិកភ័ណ្ឌស្ថាបត្យកម្ម និងនគររោបនីយកម្ម នៃទីក្រុងភ្នំពេញ

* * *

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស.រកម ០១៩៦_២៦ ចុះថ្ងៃទី ២៥ ខែ មករា ឆ្នាំ ១៩៩៦ ប្រកាសអោយប្រើច្បាប់ ស្តីពីកិច្ចការពារបេតិកភ័ណ្ឌវប្បធម៌
- បានឃើញព្រះរាជក្រមលេខ ០៤ នស.៩៤ ចុះថ្ងៃទី ១០ ខែ សីហា ឆ្នាំ ១៩៩៤ ប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំទឹកដីនគរោបនីយកម្ម និង សំណង់
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកាឆ្នាំ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស.រកត. ១០៩៤/៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស.រកត.១០៩៤/៩០ ចុះថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួល សមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ០២ នស.៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- ផ្អែកតាមតម្រូវការចាំបាច់

## សំរេច

**ប្រការ ១** : បង្កើតគណៈកម្មការរៀបចំអោយការអនុម័ត ( កំណត់ ) រាល់វិធានការការពារបេតិកភ័ណ្ឌ ស្ថាបត្យកម្ម និងនគរោបនីយកម្មនៃទីក្រុងភ្នំពេញ ។

**ប្រការ ២** : គណៈកម្មការនេះរួមមាន :

**ក)_ផ្នែកមន្ត្រីអាជ្ញាធរ :**

| | | |
|---|---|---|
| ១_ឯកឧត្តម **វណ្ណ មូលីវណ្ណ** | ទេសរដ្ឋមន្ត្រីនិងជាអនុប្រធានក្រុមប្រឹក្សាជាន់ខ្ពស់ផ្នែកវប្បធម៌ជាតិ | ប្រធាន |
| ២_ឯកឧត្តម **ឈឹម សៀកឡេង** | ប្រតិភូតំណាងរាជរដ្ឋាភិបាលប្រចាំទីក្រុងភ្នំពេញ | ជាអនុប្រធាន |
| ៣_ឯកឧត្តម **គ្រឹយ៍ បេងហុង** | អភិបាលរងរាជធានីភ្នំពេញ | ជាសមាជិក |

៤_លោក **ឆី យ៉ារ** នាយកការិយាល័យកិច្ចការនគរោបនីយកម្ម ជាលេខា

៥_លោក **ជុំម តៀន** តំណាងក្រសួងវប្បធម៌និងវិចិត្រសិល្បៈ ព្រឹទ្ធបុរសមហាវិទ្យាល័យបូរាណវិទ្យា ជាសមាជិក

៦_លោក **ឈុន សុធី** នាយកមន្ទីរសុរិយោដីក្រុងភ្នំពេញ ជាសមាជិក

៧_លោក **យស់ ឆោមវ៉ាន់ឌី** អនុប្រធានមន្ទីរនគរោបនីយកម្មនិងសំណង់ទីក្រុងភ្នំពេញ ជាសមាជិក

៨_អ្នកស្រី **ញ៉ាណ ចំណូល** អនុប្រធានមន្ទីរវប្បធម៌និងវិចិត្រសិល្បៈទីក្រុងភ្នំពេញ ជាសមាជិក

**ខ)_ផ្នែកឥស្សរៈជន**

១_សម្តេចរាជបុត្រ ព្រះរៀម **នរោត្តម បុប្ផាទេវី**

២_ឯកឧត្តម **គង់ សំអុល**

៣_ឯកឧត្តម **ឆេង ផុន**

៤_ឯកឧត្តម **ឃី តាំងលីម**

៥_ព្រះសង្ឃរាជ **ទេព វង្ស**

**ប្រការ ៣** : គណៈកម្មការនេះមានភារកិច្ចដូចតទៅ :

១_កសាងនិងលើកបញ្ជីសំណើនូវបណ្តាអាគារ និងរមណីយដ្ឋានក្នុងទីក្រុងភ្នំពេញ ដើម្បីសំរេចកំណត់បញ្ចូលក្នុងបញ្ជីអាគារសម័យបុរាណស្របតាមច្បាប់ ស្តីពីបេតិកភ័ណ្ឌវប្បធម៌ជាតិដោយផ្អែកលើបញ្ជីសារពើភ័ណ្ឌអាគារ និង រមណីដ្ឋានដែលរៀបចំដោយការិយាល័យនគរោបនីយកម្ម ។

២_លើកយោបល់អំពីបែបបទពិនិត្យសិក្សា នៃច្បាប់អនុញ្ញាតសាងសង់ជាយថាប្រភេទចំពោះអាគារទាំងនោះ សំដៅធានាគារថែទាំនិងការជួសជុលស្តារ ព្រមទាំងមធ្យោបាយត្រួតពិនិត្យដល់ទីកន្លែង សំដៅ ការពារនិងថែទាំនូវរមណីដ្ឋានទាំងឡាយ

ដែលបានកំណត់រួចហើយ ។

៣_បំផុសនិងលើកទឹកចិត្តរាល់គំនិតថែទាំបេតិកភ័ណ្ឌ ព្រមទាំងរាល់ការងារស្វែង យល់អំពីបេតិកភ័ណ្ឌនោះ ។

**ប្រការ ៤** : បណ្ដាសមាជិកគណៈកម្មការនេះ ត្រូវចូលរួមប្រជុំតាមការអញ្ជើញនិងក្រោមការដឹកនាំរបស់ប្រធាន ។

**ប្រការ ៥** : សាលាក្រុងភ្នំពេញ អគ្គលេខាធិការដ្ឋានរដ្ឋសភាជាតិ អគ្គលេខាធិការដ្ឋានព្រះបរមរាជវាំង ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ ក្រសួងធម្មការ ក្រសួងសាធារណការនិងដឹកជញ្ជូន មហាវិទ្យាល័យស្ថាបត្យកម្មនិងនគរោបនីយកម្ម មហាវិទ្យាល័យបូរាណវិទ្យា មន្ទីរនគរោបនីយកម្មនិង សំណង់ មន្ទីរស៊ិវិលយោធីក្រុង ការិយាល័យកិច្ចការនគរោបនីយកម្ម ព្រមទាំងសាម៉ីជនដូចមានចែងក្នុងប្រការ ១ មានភារកិច្ចអនុវត្តសេចក្ដីសំរេចនេះ ចាប់ពីថ្ងៃឡាយព្រះហស្ថលេខានិងចុះហត្ថលេខានេះតទៅ ។

| នាយករដ្ឋមន្ត្រីទី ១ | នាយករដ្ឋមន្ត្រីទី ២ |
|---|---|
| ព្រះហស្ថលេខានិងត្រា | ហត្ថលេខានិងត្រា |
| **នរោត្តម រណឫទ្ធិ** | **ហ៊ុន សែន** |

* * *

# III ការងារបណ្ដាក្រសួង

## ១—ទីស្ដីការរដ្ឋមន្ត្រីក្រសួងឧស្សាហកម្មរ៉ែ និង ថាមពល

**ប្រកាស**

ភ្នំពេញ,ថ្ងៃទី ២០ ខែ ឧសភា ឆ្នាំ ១៩៩៦

**ប្រកាសលេខ ៣៤៩ ឧក. ប្រក**

**រដ្ឋមន្ត្រីក្រសួងឧស្សាហកម្មរ៉ែ និង ថាមពល**